ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ

# របស់

# សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ

## ឧសភា ២០០៩ ~ ឧសភា ២០១៤

**បានទទួលការឯកភាពពីក្រុមការងារជាន់ខ្ពស់តុលាការគំរូនាថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០៩**

## សេចក្តីផ្តើម

តុលាការកម្ពុជា ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៨ ថ្មី ដែលចែងថា អំណាចតុលាការជាអំណាចឯករាជ្យ ដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ដើម្បីការពារសិទ្ធិ និងសេរីភាពពលរដ្ឋខ្មែរគ្រប់រូបដោយមិនលំអៀង។ រដ្ឋធម្មនុញ្ញក៏ចែងផងដែរថា មាន តែអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។

តុលាការនៃព្រះរាជាណាចក្រកម្ពុជា ចែកចេញជាសាលាដំបូង និងតុលាការជាន់ខ្ពស់។ សាលាដំបូងចែក ចេញជាសាលាដំបូងខេត្ត សាលាដំបូងរាជធានី និងតុលាការយោធា ហើយតុលាការជាន់ខ្ពស់ចែកចេញជា សាលាឧទ្ធរណ៍ និងតុលាការកំពូល។ យោងតាមច្បាប់ សាលាដំបូងត្រូវមានអយ្យការនៅអមជាមួយ។

## I .ជីវប្រវត្តិរបស់សាលាដំបូង និងអយ្យការខេត្តបន្ទាយមានជ័យ

ដែនដី នៃខេត្តបន្ទាយមានជ័យ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩៨៨ ដែលពីអឌិតកាលកន្លងមករបស់អាណាចក្រនៃខេត្តនេះ ជាដែនដីរបស់ខេត្តបាត់ដំបង ហើយស្ថាប័នយុត្តាធិការតុលាការត្រូវបាន តាំងនៅខេត្តបាត់ដំបងផងដែរ។ចំពោះការសម្រេចបំបែក និងបង្កើត ខេត្តបន្ទាយមានជ័យ គឺដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។

ចំពោះ ស្ថាប័នយុត្តាធិការតុលាការ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩៨៩ បន្ទាប់ពីការបង្កើតដែនដីនៃខេត្តបន្ទាយមានជ័យរួចមក ។ ចំណែកឯ អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យក៏ត្រូវបានបង្កើត ឡើងនៅពេលដំណាលគ្នានោះដែរ។

### ១.១. អំពីទីតាំងអគារ :

ឆ្នាំ១៩៨៩ អគារ នៃស្ថាប័នយុត្តាធិការតុលាការ មានលក្ខណៈជាផ្ទះល្វែងមានចំនួនពីរល្វែង មានទីតាំងស្ថិតនៅភូមិ៣ ឃុំព្រះពន្លា.ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ លុះដល់ឆ្នាំ២០០៥ ដោយស្ថានភាព អគារចាស់ទ្រុឌទ្រោម មិនអាចបំពេញការងារបាន ទើបតុលាការខេត្ត សម្រេចស្នើសុំ រាជរដ្ឋាភិបាលដើម្បីសាងសង់អគារថ្មី ដើម្បីបំពេញការងារ ។

ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ តុលាការខេត្តបន្ទាយមានជ័យ បានផ្លាស់ប្តូរទីតាំងទៅជួលអគារដើម្បីបំពេញការងារ ដោយប្រើប្រាស់ថវិការាជរដ្ឋាភិបាល អស់រយៈពេល បីឆ្នាំ ។

លុះដើម ឆ្នាំ២០០៨ ទើបរាជរដ្ឋាភិបាល បានសម្រេចសាងសង់អគារ សាលាដំបូងថ្មី រួចរាល់ជាស្ថាពរ តាមសំណើសុំរបស់តុលាការខេត្តបន្ទាយមានជ័យ មានទីតាំងបច្ចុប្បន្នស្ថិត នៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលកំពង់បំពេញការងារដូចសព្វថ្ងៃនេះ ។

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ បាននឹងកំពុងរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈកំណែទម្រង់ច្បាប់ និងតុលាការ (អាទិភាព ៥.៣.២) ដោយការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ ស្របតាមទិសដៅចំបងទាំង ១០ នៃតុលាការគំរូ ដូចខាងក្រោម :

ទិសដៅទី ១: តុលាការ ត្រូវតែជាកន្លែងដែលប្រជាពលរដ្ឋអាចប្រើប្រាស់បាន

ទិសដៅទី ២: តុលាការ មានដំណើរការប្រកបដោយតម្លាភាព

ទិសដៅទី ៣: ចៅក្រមសម្រេចសេចក្តី ដោយឯករាជ្យ

ទិសដៅទី ៤: ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីតុលាការ ត្រូវមានជំនាញវិជ្ជាជីវៈ និងមានការ យល់ ដឹងគ្រប់គ្រាន់

ទិសដៅទី ៥: ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីតុលាការ បម្រើការងារ ដោយគោរពក្រមសីលធម៌

ទិសដៅទី ៦: ការស៊ើបអង្កេត និងដំណើរការតុលាការ ត្រូវបានធ្វើឡើងដោយមិនលំអៀង យុត្តិធម៌ និង ប្រកប ដោយវិជ្ជាជីវៈ

ទិសដៅទី ៧: ភាគីទាំងសងខាង ជនរងគ្រោះ និងសាក្សី ត្រូវបានគេយកចិត្តទុកដាក់ ដោយមេត្តាធម៌ និងគោរព

ទិសដៅទី ៨: គូវិវាទមានតំណាងដែលមានប្រសិទ្ធភាព

ទិសដៅទី ៩: តុលាការមានដំណើរការប្រកបដោយសមត្ថភាព និងប្រសិទ្ធិភាព

ទិសដៅទី ១០: សាលក្រមតុលាការត្រូវបានអនុវត្ត ទៅតាមលំដាប់លំដោយ

## ទំនាក់ទំនងរវាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ផែនការយុទ្ធសាស្ត្រតុលាការគំរូ




### ១.២រដ្ឋបាលដែនដីរបស់ខេត្តបន្ទាយមានជ័យ

- ផ្ទៃដីរួមរបស់ខេត្ត : ៦៦៧.៧០០ ហិកតា
- ផ្ទៃដីបង្កបង្កើនផល : ២១៦.០០០ ហិកតា
- ផ្ទៃដីព្រៃ : ៣៥៨.៣៥០ ហិកតា
- ផ្ទៃដីបឹងបួរ : ៨០.៨៥០ ហិកតា
- ផ្ទៃដីលំនៅដ្ឋាន : ១២.៥០០ ហិកតា

- ស្រុកមាន ចំនួន ០៧ គឺ : ស្រុកមង្គលបូរី ស្រុកអូរជ្រៅ ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុក ស្វាយចេក ស្រុកថ្មពួក និងស្រុកម៉ាឡៃ ។
- ក្រុងមានចំនួន ០២ គឺ : ក្រុងសិរីសោភ័ណ និង ក្រុងប៉ោយប៉ែត ។
- ឃុំមានចំនួន៥៥ និងសង្កាត់មានចំនួន ០៩

- ភូមិមានចំនួនសរុប ៦២៥ ភូមិ ( ផ្លូវការ ) និងមិនទាន់ទទួលស្គាល់ជាផ្លូវការចំនួន២៧ ភូមិ

### ១.៣.អំពីចំនួនប្រជាពលរដ្ឋ ក្នុងឆ្នាំ២០០៨

- ប្រជាពលរដ្ឋសរុបមានចំនួន : ១៣៨.៣៣១ គ្រួសារ មនុស្សរាយ ៦៧៧.២៦៧ នាក់ ស្រីមាន ចំនួន ៣៨៨.៩០៤ នាក់ ។
- អាយុ ១៨ឆ្នាំ ឡើង : ៣៨៨. ៩១៣ នាក់ ស្រី ១៩៩.៦៩៥ នាក់
- ដង់ស៊ីតេប្រជាពលរដ្ឋគឺ ១០០ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ដែល៨០ % ជា កសិករ ។

## II.រចនាសម្ព័ន្ធសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត

### ១. ផ្នែកសាលាដំបូង

- ចៅក្រមសរុប ( ០៨ រូប ) ក្នុងនោះ :-
    - ប្រធាន ( ០១ រូប )
    - អនុប្រធាន ( ០១ រូប )
    - ចៅក្រម ( ០៦ រូប )
- ក្រឡាបញ្ជី សរុប ( ១៣ រូប ) ក្នុងនោះ :-
    - នាយកក្រឡាបញ្ជី ( ០១ រូប )
    - ក្រឡាបញ្ជី ( ១២ រូប )
- បុគ្គលិក ( ០៣ រូប )
- បុគ្គលិក ជាប់កិច្ចសន្យា ( ០៥ រូប )

### ២. ផ្នែកអយ្យការ

- ព្រះរាជអាជ្ញា សរុប ( ០៤ រូប ) ក្នុងនោះ :-
    - ព្រះរាជអាជ្ញា ( ០១ រូប )
    - ព្រះរាជអាជ្ញារង ( ០៣ រូប )
- ក្រឡាបញ្ជី សរុប ( ០៥ រូប ) ក្នុងនោះ :-
    - នាយកក្រឡាបញ្ជី ( ០១ រូប )
    - ក្រឡាបញ្ជី ( ០៤ រូប )
- បុគ្គលិក ជាប់កិច្ចសន្យា ( ០៣ រូប

# រចនាសម្ព័ន្ធចាត់តាំងបច្ចុប្បន្ន របស់
# សាលាដំបូង និង អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ



# សំណើរចនាសម្ព័ន្ធតុលាការកម្ពុជា_តុលាការជាន់ទាប



## ឧបករណ៍សម្ភារៈ និងការិយាល័យធ្វើការ

- អគារ មានពីរកន្លែង ក្នុងនោះ ( មួយកន្លែង មានលក្ខណៈជាផ្ទះល្វែង ចាស់ទ្រុឌទ្រោម បិទទ្វាចោល និង មួយកន្លែងទៀត ជាអគារថ្មី កំពុងបំពេញ ការងារ )
- សាលសវនាការ
- មន្ទីរស៊ើបសួរ
- ឃ្លាំង និង សំភារៈផ្សេងៗ មានក្នុង បញ្ជីសារពើពន្ធរបស់តុលាការ
- រដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ ( រដ្ឋបាល.គណនេយ្យ, ទទួលពាក្យបណ្តឹង, ចុះបញ្ជីបណ្តឹង,ទទួលប្រាក់បង់ពន្ធ, ឃ្លាំងវត្ថុតាង និង ឃ្លាំងរក្សាឯកសារ ព្រមទាំងសំណុំរឿង) ។

ដើម្បីឱ្យតុលាការដំណើរការបានពេញលេញ ត្រូវមានឧបករណ៍សម្ភារៈដូចខាងក្រោមៈ បន្ទប់ពិភាក្សា និង បន្ទប់សាក្សី សម្រាប់សាលសវនាការ គ្មានសំលេងរំខានក្នុងបន្ទប់ ជនអសមត្ថភាពក៏អាចប្រើប្រាស់បាន មានកន្លែង ទទួលភ្ញៀវ បន្ទប់ឃុំឃាំង ពីរដោយមានបង្គន់អនាម័យផង បង្គន់អនាម័យសាធារណៈដោយ ចែកដាច់ពីគ្នា រវាង បុរស និងស្ត្រី បន្ទប់ដាក់ឯកសារបន្ទប់រក្សាវត្ថុតាងដែលមានសុវត្ថិភាព និងមានខ្យល់ចេញចូល ច្រកចេញចូល ដែល មានសុវត្ថិភាពសម្រាប់ ចៅក្រមនៅក្នុង សាលសវនាការបង្គន់ អនាម័យសម្រាប់ បុគ្គលិកតុលាការ កន្លែងចុះបញ្ជី ធំទូលាយ.បន្ទប់ប្រជុំ.ឬបន្ទប់សម្រុះសម្រួល.បណ្ណាល័យ.ឧបករណ៍ទំនាក់ទំនង និង ក្តារខៀនបិទប្រកាសសាធារណៈ ។

## នីតិកម្ម

ការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ និងអយ្យការ គឺផ្អែកលើរដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ និងលិខិត បទដ្ឋានផ្សេងទៀត។

## ផ្នែកដែលពាក់ព័ន្ធផ្សេងៗក្នុងរដ្ឋាភិបាល

- ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- ក្រសួងយុត្តិធម៌ និង ក្រសួងនានាដែលពាក់ព័ន្ធ
- សាលាដំបូងខេត្ត.ក្រុង និង តុលាការជាន់ខ្ពស់
- សាលាខេត្ត
- នគរបាលយុត្តិធម៌ ( នគរបាល.កងរាជអាវុធហត្ថ និងអង្គភាពនានា ដែលពាក់ពន្ធ័ និងការងារ យុត្តិធម៌)
- ជំនាញកោសល្យវិច័យ
- មន្ទីរ ហិរញ្ញវត្ថុ និងមន្ទីជុំវិញខេត្ត

- រតនាគារខេត្ត
- ពន្ធនាគារខេត្ត ក្រុង
- ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**អ្នកផ្តល់សេវាសំខាន់ៗក្រៅរដ្ឋាភិបាល**

អ្នកផ្តល់សេវាសំខាន់ៗ រួមមានគណៈមេធាវី អង្គការជំនួយផ្នែកច្បាប់ និងអង្គការផ្សេងៗទៀតដែលបំរើសេវាកម្មផ្នែកច្បាប់ ។

**ហិរញ្ញវត្ថុ**

ហិរញ្ញវត្ថុត្រូវបានផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈក្រសួងយុត្តិធម៌ដែលជាអាណាប័កដើមខ្សែ គឺជាអ្នកដាក់សំណើថវិកា ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ថវិកាត្រូវបានគ្រប់គ្រងតាមរយៈរតនាគារ ខេត្តបន្ទាយមានជ័យ ។

**៣. ការវិភាគបរិយាកាស**

**អានិភាពសម្រាប់ការអភិវឌ្ឍន៍**

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត ត្រូវអនុវត្តតាមនីតិវិធីច្បាប់ដែលមានស្រាប់ និង ច្បាប់ថ្មីៗ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យមានការជឿទុកចិត្តពីប្រជាពលរដ្ឋ ។

**ព្យាករណ៍បរិយាកាសសម្រាប់ប្រាំឆ្នាំខាងមុខ**

ស្របតាម គោលនយោបាយរបស់រាជរដ្ឋាភិបាល សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត អាចព្យាករណ៍បរិយាកាស សម្រាប់ប្រាំឆ្នាំ ខាងមុខឃើញថា សេដ្ឋកិច្ចមានការរីកចំរើន ការផលិត និងសេវាកម្មក៏មានការកើនឡើង រួមជាមួយនឹងកំណើន ប្រជាពលរដ្ឋ ក៏មានការកើនឡើងជាលំដាប់ ស្របនិងការអភិវឌ្ឍន៍នូវធនធានមនុស្ស ដ៏សំបូរបែប ដែលជាកត្តាមួយ ធ្វើអោយ វិវាទផ្សេង អាចកើន ឡើងច្រើនជាលំដាប់ ហើយភាគរយនៃយុវជនក្មេងៗ ដែលជាប់ពាក់ព័ន្ធ ក្នុងរឿងក្តី នៅតុលាការក៏កើន ឡើងដែរ។ការកើនឡើងនូវការវិនិយោគបរទេស និងការគ្រប់គ្រងជនបរទេសក៏ត្រូវបានរំពឹងថាអាចនឹងនាំឱ្យមាន ការកើនឡើង នូវវិវាទផ្សេងៗ ។

អត្រានៃអ្នកចេះអក្សរ និងយល់ដឹងអំពីច្បាប់កម្ពុជាត្រូវបានព្យាករណ៍ថា នឹងមានការកើន ឡើងផងដែរ ក្នុងរយៈពេល ប្រាំឆ្នាំ ខាងមុខ ដែលជាហេតុធ្វើឱ្យមានការកើនឡើងនូវបញ្ហាត្រូវចូលតុលាការ ហើយក៏ទាមទារ នូវការផ្តល់សេវាពីសំណាក់តុលាការ និងអយ្យការឱ្យកាន់តែប្រសើរឡើង។

ការកើនឡើងនៃចំនួនមេធាវី ទាមទារនូវការធ្វើឱ្យប្រសើរឡើងនៃក៏រិតនៃការតំណាងនៅតុលាការទោះ បីជាសេវាទាំងនេះ ត្រូវបានព្យាករណ៍ នឹងកើនឡើងភាគច្រើននៅទីក្រុងធំៗក៏ដោយ សម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។

កត្តាទាំងអស់នេះ រួមទាំងច្បាប់ថ្មីៗ ដែលចេះតែកើនឡើងជាលំដាប់ នឹងនាំឱ្យមានការកើនឡើងនូវទំហំ និង បន្ទុកកាន់តែធ្ងន់ធ្ងរ ថែមទៀតសម្រាប់តុលាការ និងអយ្យការ ។

## ៤. ផែនការ

### ចក្ខុវិស័យ

តុលាការមួយឯករាជ្យ និងមានដំណើរការល្អប្រសើរ ទទួលបានការជឿទុកចិត្តពីប្រជាពលរដ្ឋ។

### បេសកកម្ម

ផ្តល់យុត្តិធម៌ ក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ដោយគោរព និង អនុវត្តតាមស្តង់ដា និង លក្ខណៈវិនិច្ឆ័យជាតិ និងអន្តរជាតិ ។

### គុណតម្លៃស្នូល

ដោយអនុលោមទៅតាមក្រមសីលធម៌ចៅក្រម នៅពេលបំពេញកិច្ចការតុលាការ ឬអយ្យការចៅក្រមត្រូវមានៈ

- **វីរិយសម្បយុត្ត** = ការបំពេញកិច្ចការប្រកបដោយវីរិយភាព
- **សុចរិតយុត្តិធម៌** = ភាពទៀងត្រង់ និងយុត្តិធម៌
- **បញ្ញត្តិគារវោ** = ការប្រតិបត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់
- **សមទណ្ឌោ** = សមភាពនៃទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា

- **បញ្ញាវុធវិនិច្ឆ័យ** = ការសម្រេចសេចក្ដីដែលប្រកបដោយបញ្ញា និងភាពឆ្លាតវៃ

***ត្រូវជៀសវាងនូវអគតិទាំង៤ គឺ*** :

- **ឆន្ទាគតិ** = លំអៀងព្រោះស្រលាញ់
- **ទោសាគតិ** = លំអៀងព្រោះទោសៈ ឬស្អប់
- **ភយាគតិ** = លំអៀងព្រោះភ័យខ្លាច
- **មោហាគតិ** = លំអៀងព្រោះមោហៈ ល្ងង់ អវិជ្ជា

## <u>រចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រ</u>

**ដើម្បីសំរេចបេសសកកម្មនេះ តុលាការបានកំណត់ទិសដៅចំនួន (បួន) ដូចខាងក្រោម :**

១. ការគ្រប់គ្រងរឿងក្ដីយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ

២. ការគ្រប់គ្រងរឿងក្ដីយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី

៣. រដ្ឋបាលសាលាដំបូង និងអយ្យការប្រកបដោយប្រសិទ្ធភាព

៤. ការគ្រប់គ្រងសាលាដំបូង និងអយ្យការឱ្យមានប្រសិទ្ធភាព

## <u>ទិសដៅទី១: ការគ្រប់គ្រងរឿងក្ដីយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ</u>

### គោលបំណងទី១.១: បង្កើតប្រព័ន្ធចុះបញ្ជីឱ្យមានលក្ខណៈល្អប្រសើរ

**យុទ្ធសាស្ត្រ:**

១.១.១ ការបង្កើត ពិធីសារទទួល និងផ្ដល់ពត៌មាន និងការចុះបញ្ជី ជាមួយក្រសួងយុត្តិធម៌

១.១.២ បង្កើតទីកន្លែងទទួល និងផ្ដល់ពត៌មាន

១.១.៣ ការបង្កើតប្រព័ន្ធ ចុះបញ្ជីអេឡិត្រូនិច និងការអនុវត្តប្រព័ន្ធ ចុះបញ្ជីដោយដៃ

១.១.៤ ធានា លើការជ្រើសរើស និងបណ្ដុះបណ្ដាល បុគ្គលិកលើជំនាញ ចុះបញ្ជីអេឡិត្រូនិច និង ការ អនុវត្ត ប្រព័ន្ធ ចុះបញ្ជីដោយដៃ

### គោលបំណងទី១.២: ពង្រឹងប្រព័ន្ធបែងចែករឿងក្ដី

**យុទ្ធសាស្ត្រ :**

## ក. បង្កើតប្រព័ន្ធបែងចែករឿងក្តី របស់អយ្យការ

១.២.១ ពង្រឹងតួនាទីពិនិត្យតាមដាន និងត្រួតពិនិត្យដោយព្រះរាជអាជ្ញា

១.២.២ រៀបចំ និងអនុវត្ត ការបែងចែកសំណុំរឿង តាមលំដាប់លេខរៀង

១.២.៣ រៀបចំ និងអនុវត្តប្រពន្ធ័ នៃការបែងចែក កិច្ចការអាជ្ញាសាលា

## ខ. បង្កើតប្រព័ន្ធបែងចែករឿងក្តី របស់តុលាការ

១.២.៤ រក្សា និងពង្រឹងប្រព័ន្ធបែងចែករឿងព្រហ្មទណ្ឌ នៅចៅក្រមដែលមានស្រាប់

## គោលបំណងទី១.៣៖ ការស៊ើបអង្កេតបឋម និងការបើកការស៊ើបសួរ ឱ្យស្របទៅតាមនីតិវិធី ព្រហ្មទណ្ឌ

## យុទ្ធសាស្ត្រ

### ក. ការស៊ើបអង្កេតបឋម និងការបើកការស៊ើបសួរ របស់ព្រះរាជអាជ្ញា

១.៣.១ ធានា ឱ្យមានយន្តការតាមដានត្រួតពិនិត្យ កិច្ចការរបស់នគរបាលយុត្តិធម៌ ដោយព្រះរាជអាជ្ញា

១.៣.២ ធ្វើអោយប្រសើរឡើង នូវប្រពន្ធ័នៃការបញ្ជូនដីកានិង លិខិតផ្សេងៗ ដើម្បីធានាអោយជនជាប់ពាក់ពន្ធ័ក្នុងរឿងក្តី អាចចូលខ្លួនមកកាន់តុលាការ តាមការកំណត់របស់តុលាការ ។

១.៣.៣ បង្កើនចំនួនព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីបុគ្គលិក ដែលមានសមត្ថភាពអោយបានសមល្មម និង ទំហំការងារ ។

១.៣.៤ ធានាឱ្យមានអាជ្ញាសាលា ដែលមានសមត្ថភាពអោយបានសមល្មម និង ទំហំការងារ ។

១.៣.៥ ធានា ឱ្យមានអ្នកជំនាញ ( អ្នកបកប្រែភាសា.មេធាវី.ទេព្យ ។ ល ។ ) ដើម្បីជួយការងារ តុលាការ ក្នុងកិច្ចការ ស៊ើបអង្កេតបឋមរបស់អយ្យការ ។

១.៣.៦ ធានាប្រសិទ្ធិភាព ក្នុងការបញ្ជូនសំណុំរឿងទៅ ចៅក្រមស៊ើបសួរ ។

### ខ. ការស៊ើបសួរ របស់ចៅក្រមស៊ើប

១.៣.៧ ធានាអោយមាន មេធាវី ដោយសហការជាមួយគណៈមេធាវី និង អង្គការជំនួយផ្នែកច្បាប់ ទៅ តាមនិតិវិធីព្រហ្មទណ្ឌ ។

១.៣.៨ បង្កើនចំនួន.ចៅក្រម.ក្រឡាបញ្ជី និងមន្ត្រីបុគ្គលិកដែលមានសមត្ថភាពអោយបានសមល្មម និង ទំហំការងារ ។

១.៣.៩ បង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ ដើម្បីជំរុញកិច្ចការរបស់ចៅក្រមស៊ើបសួរ ទៅតាមនិតិវិធីព្រហ្មទណ្ឌ អោយបានល្អប្រសើរ ។

១.៣.១០ ធានាអោយមាន មធ្យោបាយ និងធនធាន ដើម្បី ផ្តល់លក្ខណៈងាយស្រួលដល់ការស្វែង រកវត្ថុតាងដល់កិច្ចការ ស៊ើបសួរ ។

## គោលបំណងទី១.៤: សវនាការប្រកបដោយយុត្តិធម៌ ស្របតាមស្តង់ដា នៃតុលាការកម្ពុជាដែលបានបង្កើតឡើង

### យុទ្ធសាស្ត្រ

១.៤.១ រៀបចំធ្វើប្រតិទិន ដើម្បីកំណត់កម្មវិធីជំនុំជំរះអោយមានប្រសិទ្ធិភាព

១.៤.២ ធានាអោយមានកន្លែងសវនាការ និង សំភារៈបរិក្ខាអោយបានសមរម្យ គ្រប់គ្រាន់តាម តម្រូវការក្នុងការជំនុំជំរះរឿងក្តី

១.៤.៣ បង្កើន និងធានាអោយបាន នូវសិទ្ធិរបស់ ជនជាប់ចោទ និងជនរងគ្រោះជាកុមារ ក្នុងពេល សវនាការ

១.៤.៤ ចេញសំរង់សាលក្រម ភ្លាមទៅពន្ធនាគារ

១.៤.៥ បង្កើន និងត្រួតពិនិត្យអំពីសាលក្រមសម្រេចព្យួរទោស

## គោលបំណងទី១.៥: ការអនុវត្តន៍សាលក្រមឱ្យបានត្រឹមត្រូវតាមច្បាប់

### យុទ្ធសាស្ត្រ

១.៥.១ ធ្វើអោយប្រសើរឡើង នូវការអនុវត្តទោស សំរាប់ទណ្ឌិត និងពិរុទ្ធជន

***សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី១***

១. ប្រព័ន្ធចុះបញ្ជីព្រហ្មទណ្ឌថ្មីត្រូវបានបង្កើត និងរក្សា

២. សំណុំរឿងត្រូវបានបែងចែកតាមប្រព័ន្ធលំដាប់ និងតាមប្រតិទិនប្រចាំឆ្នាំរបស់តុលាការ

៣. ភាគរយនៃសំណុំរឿងដែលមានអ្នកតំណាងត្រឹមត្រូវ ( ត្រូវមានជាចាំបាច់)

៤. ចំនួនសវនាការដែលបានប្រព្រឹត្តធ្វើឡើង

៥. ចំនួនសំណុំរឿងដែលបានបិទ

៦. ឧបករណ៍សម្ភារៈ និងកន្លែងសាក្សីជាអនីតិជនត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត

៧. រាល់សាលក្រមតុលាការ និងរបាយការណ៍សង្ខេបត្រូវបានបញ្ជូនទៅក្រសួងយុត្តិធម៌

៨. រាល់សំរង់សាលក្រម និងសាលក្រមស្ថាពរត្រូវបានបញ្ជូនទៅពន្ធនាគារ

១០.ទណ្ឌិត និងជនជាប់ចោទត្រូវបានដោះលែង តាមពេលកំណត់

**ទិសដៅទី២: ការគ្រប់គ្រងរឿងក្ដីយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី**

**គោលបំណងទី២.១: ការចុះបណ្ដឹងឱ្យបានសមស្រប និងមានប្រសិទ្ធិភាព**

**យុទ្ធសាស្ត្រ :**

២.១.១ បង្កើតទីកន្លែងទទួល និងផ្ដល់ពត៌មាន និងការចុះបណ្ដឹង

២.១.២ ការបង្កើតប្រព័ន្ធ ចុះបញ្ជីអេឡិត្រូនិច និងការអនុវត្តប្រព័ន្ធ ចុះបញ្ជីបណ្ដឹងដោយដៃ

២.១.៣ ធានា លើការជ្រើសរើស និង បណ្ដុះបណ្ដាល បុគ្គលិកលើជំនាញ ចុះបញ្ជីអេឡិត្រូនិច និង ការអនុវត្តប្រព័ន្ធ ចុះបញ្ជីបណ្ដឹងដោយដៃ

**គោលបំណងទី២.២: ការពិនិត្យលើបណ្ដឹងឱ្យមានប្រសិទ្ធិភាព**

**យុទ្ធសាស្ត្រ :**

២.២.១ ធានាអោយមាន ការត្រួតពិនិត្យលើបណ្ដឹង អោយបានល្អប្រសើរ ទៅតាមនិតិ វិធីរដ្ឋប្បវេណី

២.២.២ ធានាលើការជ្រើសរើស និងបណ្ដុះបណ្ដាលមន្ត្រី ក្នុងការត្រួតពិនិត្យ បណ្ដឹង

**គោលបំណងទី២.៣: ការបរិច្ឆេទត្រៀមទាញហេតុផល ត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធិភាព**

**យុទ្ធសាស្ត្រ:**

២.៣.១ ធ្វើអោយប្រសើរឡើង នូវប្រពន្ធ័ នៃការបញ្ជូន ដីកានិង លិខិតផ្សេងៗ ដើម្បី ធានាអោយ ជនជាប់ពាក់ពន្ធ័ ក្នុងរឿងក្តី អាចចូលខ្លួនមកកាន់តុលាការ តាមការកំណត់របស់តុលាការ

២.៣.២ ធានាអោយមានឧបករណ៏សំភារៈ និង បរិក្ខាគ្រប់គ្រាន់សំរាប់បំពេញ ការងារ ក្នុងនិតិវិធីត្រៀមទាញហេតុផល

២.៣.៣ ធានា ប្រសិទ្ធិភាពក្នុងការបន្ត សំណុំរឿងទៅ ធ្វើនិតិវិធី ទាញហេតុផល ដោយផ្ទាល់មាត់

**គោលបំណងទី២.៤: ការបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាព**

**យុទ្ធសាស្ត្រ:**

២.៤.១ ធ្វើអោយប្រសើរឡើង នូវប្រពន្ធ័ នៃការបញ្ជូន ដីកានិង លិខិតផ្សេងៗ ដើម្បីធានាអោយ ជនជាប់ពាក់ពន្ធ័ ក្នុងរឿងក្តី អាចចូលខ្លួនមកកាន់តុលាការ តាម ការកំណត់ របស់តុលាការ

២.៤.២ ធានាអោយមានឧបករណ៏សំភារៈ និងបរិក្ខាគ្រប់គ្រាន់ សំរាប់បំពេញ ការងារក្នុងនិតិវិធី ទាញហេតុផល

២.៤.៣ ធានា ប្រសិទ្ធិភាពក្នុងការបន្តធ្វើនិតិវិធីទាញហេតុផលដោយផ្ទាល់មាត់

**គោលបំណងទី២.៥: ការចេញសាលក្រមទៅតាមនីតិវិធី**

**យុទ្ធសាស្ត្រ:**

២.៥.១ ធានាភាពយុត្តិធម៌ ក្នុងការចេញសាលក្រមដល់ភាគី ដើម្បីបង្កើនទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋ

២.៥.២ ធានាការអនុវត្ត ក្នុងការចេញសាលក្រម អោយបានទាន់ចិត្ត និងមានប្រសិទ្ធិភាព ទៅតាម និតិវិធីរដ្ឋប្បវេណី

២.៥.៣ បង្កើតប្រព័ន្ធ តាមដាន ត្រួតពិនិត្យ និងរក្សាទុក អំពីសេចក្តីសម្រេច នៃសាលក្រម ដើម្បីផ្តល់លក្ខណៈងាយស្រួល ដល់ការគ្រប់គ្រងរឿងក្តី

**គោលបំណងទី២.៦ : ការជូនដំណឹងឱ្យមានប្រសិទ្ធិភាព**

**យុទ្ធសាស្ត្រ**

២.៦.១ ធ្វើអោយប្រសើរឡើង នូវប្រព័ន្ធនៃការជូនដំណឹងរបស់តុលាការ ដើម្បីធានា អោយជនជាប់ព័ន្ធក្នុងរឿងក្តី អាចទទួលពតិមាន នៅគ្រប់ដំណាក់កាលនៃនីតិវិធីក្តី

**គោលបំណងទី២.៧: ការអនុវត្តសាលក្រម និងសេចក្តីសំរេចផ្សេងៗឱ្យមានប្រសិទ្ធភាព**

**យុទ្ធសាស្ត្រ**

២.៧.១ ធ្វើអោយប្រសើរឡើង នូវការអនុវត្តរាល់សេចក្តីសំរេចរបស់តុលាការ ដោយផ្អែកទៅតាមក្រមនិតីវិធីរដ្ឋប្បវេណី ។

***<u>សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី២</u>***

១. ប្រព័ន្ធចុះបញ្ជីរឿងក្តីរដ្ឋប្បវេណីថ្មីត្រូវបានបង្កើត និងរក្សា

២. ប្រព័ន្ធនៃការពិនិត្យសំណុំរឿងរដ្ឋប្បវេណីត្រូវបានបង្កើត និងរក្សា

៣. សំណុំរឿងរដ្ឋប្បវេណីត្រូវបានបែងចែកទៅតាមប្រតិទិនប្រចាំឆ្នាំរបស់តុលាការ

៤. ភាគរយនៃរឿងក្តីដែលភាគី សាក្សី និងអ្នកជំនាញដែលខកខានមិនចូលមកតុលាការ បន្ទាប់ពីទទួលបានការជូនដំណឹង

៥. ចំនួនសវនាការ

៦. រាល់សេចក្តីរបស់តុលាការ និងរបាយការណ៍សង្ខេបត្រូវបានបញ្ជូនទៅក្រសួងយុត្តិធមិ

៧. ភាគរយនៃសំណុំរឿងដែលបានបិទ បន្ទាប់ពីអនុវត្តចប់ ។

## ទិសដៅទី៣ : រដ្ឋបាលសាលាដំបូង និងអយ្យការទទួលបានការគាំទ្រត្រឹមត្រូវ និង ដំណើរការប្រកបដោយប្រសិទ្ធិភាព

**គោលបំណងទី៣.១: រដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ ដែលអាចគាំទ្រដល់ដំណើរការរបស់ តុលាការ និងអយ្យការ**

**យុទ្ធសាស្ត្រ**

៣.១.១ មន្ត្រីមានសមត្ថភាពក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាល ( ព័តិមានវិទ្យា គ្រប់គ្រង បុគ្គលិក ប្រតិទិន តុលាការ ផែនការការងារ បណ្តុះបណ្តាល ប្រជុំ គ្រប់គ្រង ហិរញ្ញវត្ថុ ស្ថិតិរបាយការណ៍ )

**គោលបំណងទី៣.២: ការរៀបចំថវិកាឱ្យបានគ្រប់គ្រាន់ និងការគ្រប់គ្រងធ្វើឡើងទាន់ពេលវេលា ដើម្បីឆ្លើយតបទៅនឹងការតម្រូវរបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**យុទ្ធសាស្ត្រ:**

៣.២.១ ធានាក្នុងការធ្វើផែនការថវិការប្រចាំឆ្នាំស្របតាមតម្រូវការចាំបាច់និងនិតិ.អោយទាន់ពេលវេលា និងមានប្រសិទ្ធិភាព

៣.២.២ ធានាអោយមានយន្តការ រៀបចំ និងអនុវត្តប្រព័ន្ធថែរក្សា សៀវភៅបញ្ជីចំណូល ចំណាយ និង ឯកសារផ្សេង១ ដែលបានបិទទុក

**គោលបំណងទី៣.៣: ទទួលនិងរក្សាឱ្យមានមធ្យោបាយ និងសំភារៈបរិក្ខាគ្រប់គ្រាន់ ក្នុង កិច្ចការតុលាការ និង អយ្យការ**

**យុទ្ធសាស្ត្រ:**

៣.៣.១ ធានាអោយមានការធ្វើផែនការ ថែរក្សា និងការស្នើសុំបន្ថែម តាមការចាំបាច់

៣.៣.២ ធានា បង្កភាពងាយស្រួល ដល់ជនពិការ និងជនបាត់បង់សមត្ថភាព

៣.៣.៣ ធានាអោយមានឧបករណ៏សំភារៈ និងបរិក្ខាគ្រប់គ្រាន់ សំរាប់បំរើការរដ្ឋបាលតុលាការ និង អយ្យការ

## គោលបំណងទី៣.៤៖ ផ្តល់ធនធានមនុស្សគ្រប់គ្រាន់ ប្រកបដោយសមត្ថភាពឆ្លើយតប នៅនឹងការងារ

### យុទ្ធសាស្ត្រ៖

៣.៤.១ ធានា បង្កើនចំនួន ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ទៅតាមទំហំការងារ ជាក់ស្តែង

៣.៤.២ បង្កើនប្រាក់ឧបត្ថម ឬ ប្រាក់បៀវត្ស ដល់មន្ត្រីតុលាការ.អោយបានសមរម្យ ដើម្បីធានាបាននូវប្រសិទ្ធិភាពការងារ

៣.៤.៣ ផ្តល់លទ្ធភាពដល់ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីបុគ្គលិក ក្នុងការចូលរួមវគ្គបណ្តុះបណ្តាល ផ្សេងៗ

៣.៤.៤ កំណត់ និង ជ្រើសរើសមន្ត្រីបុគ្គលិករដ្ឋបាល .ដើម្បីជួយដល់កិច្ចការ .តុលាការ និង អយ្យការ ជាពិសេស ក្នុងប្រព័ន្ធ បច្ចេកវិទ្យា

## គោលបំណងទី៣.៥ ៖ អនុវត្ត ការប្រមូលប្រាក់ពន្ធចូលថវិការរដ្ឋ ឱ្យមានប្រសិទ្ធិភាព

### យុទ្ធសាស្ត្រ

៣.៥.១ ធានា អោយមានមន្ត្រី បុគ្គលិក ដែលមានសមត្ថភាពក្នុងការចុះបញ្ជី ដោយដៃ ឬប្រព័ន្ធបច្ចេក វិទ្យាលើការត្រួតពិនិត្យប្រាក់ពន្ធដែលត្រូវបង់ចូលថវិការរដ្ឋដោយផ្អែកលើក្រមនិតិវិធីរដ្ឋប្បវេណី

៣.៥.២ ធានាក្នុងការធ្វើផែនការថវិការចំណូលនិង បង់ប្រាក់ចូលថវិការរដ្ឋ អោយទាន់ពេលវេលា និង មានប្រសិទ្ធីភាព ដោយផ្អែកលើ ការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ និងតាមក្រម និតិវិធី រដ្ឋប្បវេណី

៣.៥.៣ ធានាអោយមានយន្តការ រៀបចំ និងអនុវត្តប្រព័ន្ធថែរក្សា សៀវភៅបញ្ជីចំណូល ចំណាយ និងឯកសារផ្សេងៗ ដែលបានបិទទុក និងរបាយការណ៏ថវិការចំណូលជាក់ស្តែងដែលត្រូវរាយការណ៏

៣.៥.៤ ធានាឱ្យមានការគ្រប់គ្រងទ្រព្យទាំងអស់ ដែលត្រូវតុលាការសម្រេច រឹបអូសជាទ្រព្យសម្បត្តិរដ្ឋត្រូវបង់ ចូលថវិការរដ្ឋ ដោយផ្អែកលើក្រមនិតិវិធី និងគោលការណ៏ច្បាប់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***<u>សូចនាករគោមដានការអនុវត្តន៍សម្រាប់ទិសដៅទី៣</u>***

១. ចំនួនបុគ្គលិកដែលមានសមត្ថភាពប្រៀបធៀបនឹងតម្រូវការរបស់តុលាការ

២. ការដាក់សំណើថវិកាប្រចាំឆ្នាំទាន់ពេលវេលា និងបានល្អត្រឹមត្រូវ

៣. ចំនួន និងប្រភេទនៃការបណ្តុះបណ្តាលត្រូវបានអនុវត្តជារៀងរាល់ឆ្នាំ

៤. ចំនួនបុគ្គលិកដែលមានសមត្ថភាពអាចប្រើឧបករណ៍ទំនាក់ទំនងបែបទំនើប

៥. សម្ភារៈឧបករណ៍សម្រាប់ជនអសមត្ថភាពត្រូវបានបង្កើតឡើង និងដំណើរការ

៦. .ការធ្វើផែនការ និងការបង់ចំណូលថវិកាប្រចាំឆ្នាំទាន់ពេលវេលា និងបានល្អត្រឹមត្រូវ

៧ .រៀបចំ និងអនុវត្តផែនការថែរក្សាទ្រព្យសម្បត្តិគ្រប់ប្រភេទទាំងអស់ របស់រដ្ឋ

## ទិសដៅទី៤: ការគ្រប់គ្រងសាលាដំបូង និងអយ្យការប្រកបដោយប្រសិទ្ធិភាព

## គោលបំណងទី៤.១: ការទទួល និងផ្តល់ព័ត៌មានឱ្យមានប្រសិទ្ធិភាព

### យុទ្ធសាស្ត្រ

៤.១.១ ធានា អោយមានមន្ត្រីបុគ្គលិក ដែលមានសមត្ថភាព ក្នុងកាទទួល និងផ្តល់ពតិមាន ពីកិច្ចការរបស់តុលាការ

៤.១.២ ធានា ទីកន្លែងសមរម្យ ងាយស្រួលក្នុងការទទួល និងផ្តល់ពតិមាន

៤.១.៣ ធានាអោយមានឧបករណ៍ទំនាក់ទំនងផ្សេងៗ (internet, brochure, workshops)¦ ដើម្បីបង្កភាពងាយស្រួលក្នុងការទទួល និងផ្តល់ពតិមាន

៤.១.៤ ធានា អោយមាននិតិវិធី ផ្តល់ពតិមាន តាមគ្រប់រូបភាព ដល់សាធារណៈជន ទូទៅ

## គោលបំណងទី៤.២: ការគ្រប់គ្រង និងត្រួតពិនិត្យ ការចុះបញ្ជីនូវនៅត្រូវបានធ្វើឡើងស្រប នៅតាមនីតិវិធី

### យុទ្ធសាស្ត្រ

៤.២.១ ធានា អោយមាន.មន្ត្រី បុគ្គលិក ដែលមានសមត្ថភាពក្នុងការចុះបញ្ជី ដោយដៃ ឬប្រព័ន្ធ បច្ចេកវិទ្យា

៤.២.២ រៀបចំ និងអនុវត្តប្រព័ន្ធតាមដាន និងពញ្ញាក់រំលឹកដាស់តឿន ដល់មន្ត្រី ដែលទទួលបន្ទុក កិច្ចការតុលាការ និងអយ្យការ

**គោលបំណងទី៤.៣: សមត្ថភាពនៃការគ្រប់គ្រងទូទៅរបស់តុលាការ និងអយ្យការ**

**យុទ្ធសាស្ត្រ**

៤.៣.១ ធានាអោយមានរបបប្រជុំ ស្របតាមប្រក្រតិទិន ដែលបានកំណត់

៤.៣.២ ធានាអោយមានមន្ត្រីដែលមានសមត្ថភាព ក្នុងកិច្ចការគ្រប់គ្រង វិភាគទិន្ន័យ និង ចាត់ចែង ការងារ តុលាការ

៤.៣.៣ បង្កើនសមត្ថភាព មន្ត្រី. ក្នុងកិច្ចការធ្វើផែនការ របស់តុលាការអោយមាន ប្រសិទ្ធិភាព

**គោលបំណងទី៤.៤: រៀបចំគ្រប់គ្រងការតម្កល់ឯកសារឱ្យមានប្រសិទ្ធិភាព (ការគ្រប់គ្រង សំណុំរឿង និង ឯកសារផ្សេងៗ )**

**យុទ្ធសាស្ត្រ**

៤.៤.១ ធានាអោយមានយន្តការ រៀបចំ និងអនុវត្តប្រព័ន្ធថែរក្សា សំណុំរឿង សៀវភៅបញ្ជី និង ឯកសារ ផ្សេងៗ ដែលបានបិទទុក

៤.៤.២ ធានា អោយមាន ទីកន្លែងសមរម្យ សំរាប់តំកល់ឯកសារ

៤.៤.៣ ធានា អោយមានមន្ត្រីដែលមានសមត្ថភាព ក្នុងការគ្រប់គ្រង រៀបចំ រក្សាទុក ឯកសារ

**គោលបំណងទី៤.៥: លេខាធិការដ្ឋានដែលបំពេញមុខងារបានល្អ**

**យុទ្ធសាស្ត្រ:**

៤.៥.១ បង្កើតលេខាធិការដ្ឋានសម្រាប់តុលាការ និង អយ្យការ ។

៤.៥.២ បង្កើតប្រតិទិនគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពឱ្យបានទាន់ពេលវេលា ។

៤.៥.៣ ធ្វើគោលនយោបាយ និងការគ្រប់គ្រងទូទៅ ដោយអនុវត្តតាមប្រតិទិនគ្រប់គ្រងផែនការសកម្មភាព ការងារ ។

៤.៥.៤ ជំរុញឱ្យមានការធ្វើយុទ្ធសាស្ត្រនិង ផែនការកម្មវិធី ព្រមទាំង ផែនការដ៏ទៃទៀត ឱ្យស្របតាម មគ្គុទេសក៍ នៃការធ្វើផែនការក្នុងវិស័យយុត្តធម៌ ។

៤.៥.៥ រៀបចំនីតិវិធីចំណាយហិរញ្ញវត្ថុ។

***<u>សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី៤</u>***

១. បង្កើត និងដំណើរការកន្លែងទទួលភ្ញៀវ

២. បង្កើត និងប្រើជាប្រចាំនូវប្រព័ន្ធរំលឹកដាស់តឿន និងតាមដានសំណុំរឿង

៣. បង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងសំណុំរឿង និងគ្រប់គ្រងវត្ថុតាង

៤. បង្កើត និងថែរក្សាបណ្ណាល័យតុលាការ

៥. បង្កើត និងថែរក្សាប្រព័ន្ធតំកល់ឯកសារ

៦. ចំនួនកម្មវិធីនៃការសម្របសម្រួល និងផ្តល់ពតិមានផ្សេងៗត្រូវបានអនុវត្ត ។